**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារពិសេសថ្នាក់ជាតិ ទទួលបន្ទុកកិច្ចការអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារពិសេសថ្នាក់ជាតិ ទទួលបន្ទុកកិច្ចការអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ប៊ិន ឈិន** | ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជារដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តម | **វង្សី វិស្សុត** | រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣. ឯកឧត្តមនាយឧត្តមសេនីយ៍ | **តូច ស៊ីផាន** | អនុរដ្ឋលេខាធិការនៃក្រសួងការពារជាតិ | អនុប្រធាន |

| | | |
|---|---|---|
| ៤. ឯកឧត្តម **ចាន់ សុធី** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥. ឯកឧត្តម **សេង ឡៀង** | អនុរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៦. ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការ បញ្ជាការដ្ឋានអង្គរក្ស | អនុប្រធាន |
| ៧. ឯកឧត្តមនាយឧត្តមសេនីយ៍ **គឹម ប៊ុនថាន** | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ | អនុប្រធាន |
| ៨. ឯកឧត្តមនាយឧត្តមសេនីយ៍ **ខេង សុមេធ** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៩. ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** | នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការរង កងទ័ពជើងគោក | អនុប្រធានប្រចាំការ |
| ១០. ឯកឧត្តម **ហាវ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១. ឯកឧត្តម **គឹម សេតានា** | ប្រធានអាជ្ញាធរជាតិព្រះវិហារ | សមាជិក |
| ១២. ឯកឧត្តម **ម៉ុម សារឿន** | អភិបាលខេត្តស្ទឹងត្រែង | សមាជិក |
| ១៣. ឯកឧត្តម **ស ថាវី** | អភិបាលខេត្តឧត្តរមានជ័យ | សមាជិក |
| ១៤. ឯកឧត្តម **អ៊ុន ចាន់ដា** | អភិបាលខេត្តព្រះវិហារ | សមាជិក |
| ១៥. ឯកឧត្តម **ងួន រតនៈ** | អភិបាលខេត្តបាត់ដំបង | សមាជិក |
| ១៦. ឯកឧត្តម **ស្អូន បវរ** | អភិបាលខេត្តបន្ទាយមានជ័យ | សមាជិក |
| ១៧. ឯកឧត្តម **យន្ត មីន** | អភិបាលខេត្តព្រះសីហនុ | សមាជិក |
| ១៨. លោកជំទាវ **មិថុនា ភូថង** | អភិបាលខេត្តកោះកុង | សមាជិក |
| ១៩. ឯកឧត្តមឧត្តមសេនីយ៍ឯក **ស្រី ឌឹក** | នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការ កងពលធំអន្តរាគមន៍លេខ ៣ | សមាជិក |
| ២០. ឯកឧត្តមឧត្តមសេនីយ៍ឯក **ព្រហ្ម ឌិន** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគពិសេស | សមាជិក |
| ២១. ឯកឧត្តមឧត្តមសេនីយ៍ឯក **ហួត ឈាង** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ១ | សមាជិក |
| ២១. ឯកឧត្តមឧត្តមសេនីយ៍ឯក **ជឿន សុវណ្ណថា** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ២ | សមាជិក |
| ២២. ឯកឧត្តមឧត្តមសេនីយ៍ឯក **យឿង សុខុន** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគទី ៣ | សមាជិក |
| ២៣. ឯកឧត្តមឧត្តមសេនីយ៍ឯក **ជា ម៉ន** | មេបញ្ជាការរងកងទ័ពជើងគោក | |

| | | |
|---|---|---|
| | និងជាមេបញ្ជាការយោធភូមិភាគទី ៤ | សមាជិក |
| ២៤. ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុន សេខ** | មេបញ្ជាការរងកងទ័ពជើងគោក<br>និងជាមេបញ្ជាការយោធភូមិភាគទី ៥ | សមាជិក |
| ២៥. ឯកឧត្តមឧត្តមនាវីឯក **ស្រ៊ុន សារឿន** | មេបញ្ជាការរងកងទ័ពជើងទឹក<br>និងជាមេបញ្ជាការបញ្ជាការដ្ឋានការពារកោះឆ្នេរ | សមាជិក |
| ២៦. ឯកឧត្តម **នូច សុខសម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |
| ២៧. ឯកឧត្តម **ហោង ស៊ីនឿន** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |
| ២៨. ឯកឧត្តមឧត្តមសេនីយ៍ត្រី **ម៉ឹង មករា** | មេបញ្ជាការរងនាយសេនាធិការ<br>បញ្ជាការដ្ឋានជាតិ ក.ព.ប.ភ | លេខាធិការ |
| ២៩. លោកឧត្តមសេនីយ៍ត្រី **ម៉ុក ច័ន្ទសុធា** | អនុប្រធាននាយកដ្ឋាននៃ<br>នាយកដ្ឋានពិសេស ក.ព.ប.ភ | លេខាធិការ |
| ៣០. លោកវរសេនីយ៍ឯក **មៃ ស៊ីផន** | នាយកការិយាល័យរដ្ឋបាលនៃបញ្ជាការដ្ឋានជាតិ ក.ព.ប.ភ | លេខាធិការ |
| ៣១. លោកស្រី **ម៉ី សាវី** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានពិសេស ក.ព.ប.ភ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងថវិកាពិសេសសម្រាប់កិច្ចការអធិបតេយ្យ ដែលស្ថិតក្រោមបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី
- សហការជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីអនុវត្តការងារពាក់ព័ន្ធនឹងអធិបតេយ្យភាពឱ្យទទួលបានជោគជ័យ និង ប្រសិទ្ធភាពខ្ពស់
- ធ្វើរបាយការណ៍ជាប្រចាំជូនរាជរដ្ឋាភិបាល។

**ប្រការ ៣.-**

ការប្រើប្រាស់ថវិកាពិសេសសម្រាប់កិច្ចការអធិបតេយ្យ ត្រូវអនុវត្តតាមគោលការណ៍ និងវិសាលភាព ដូចខាងក្រោម៖

- សម្រាប់ចំណាយលើមុខសញ្ញាដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការងារអធិបតេយ្យ ជាពិសេសទិសព្រំដែនជាមួយឡាវ ថៃ និង ព្រំដែនទឹក លើកលែងប្រាក់បំប៉នប្រយុទ្ធប្រចាំខែបន្ថែម
- សម្រាប់ចំណាយលើមុខសញ្ញាចាំបាច់ផ្សេងទៀតពាក់ព័ន្ធនឹងការងារអធិបតេយ្យ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ ៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកក្នុងការពិនិត្យ និងផ្តល់យោបល់ជូននាយករដ្ឋមន្ត្រី ដើម្បីពិនិត្យ និងសម្រេច លើសំណើចំណាយរបស់ក្រុមការងារ និងទទួលបន្ទុកក្នុងការបើកផ្តល់ថវិកាជូនក្រុមការងារ ដើម្បីអនុវត្តទៅតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

**ប្រការ ៥.-**

- ក្រុមការងារនេះ អាចអញ្ជើញសមាជិកបន្ថែមបានតាមការចាំបាច់ និងត្រូវចូលរួមប្រជុំក្រុមការងារ តាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន
- ក្រុមការងារនេះ អាចប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦.-**

សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្ត និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៦ រោច ខែ មាឃ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ